# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់ទី២៣

**សាលាខេត្តបាត់ដំបង**

**លេខ :** ៦៦៤/១៦ ស.ស.ព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧

សាលាខេត្តបាត់ដំបង នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ :

- ប្រភេទទី១ អ្នកទទួលការសំណង់ទូទៅ ( ការងារសំណង់និងការងារបេតុង... ។ល។ )
- ប្រភេទទី២ អ្នកទទួលការការងារដី ( ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម... ។ល។ )
- ប្រភេទទី៣ អ្នកទទួលការឯកទេស ( អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេសឧទាហរណ៍ អណ្តូងស្នប់... ។ល។ )

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និង សម្ភារៈបរិក្ខារគ្រប់គ្រាន់ដូចមាន បរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិច០២ ក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយ ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេច។ អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថាមាន ការពាក់ព័ន្ធនឹង ការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការ បញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ **ទីចាត់ការផែនការ និងវិនិយោគនៃ សាលាខេត្តបាត់ដំបង** ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់**ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ៥ និង ៣០នាទីល្ងាច** ។ ចំពោះអ្នកទទួលការ ដែលមានឈ្មោះក្នុងឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និង វិនិយោគដោយឥតបង់ថ្លៃ ដែលមានអាសយដ្ឋានស្ថិតនៅសាលាខេត្តបាត់ដំបង ( **អាគារ B** ) ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប ឬទំនាក់ទំនងតាមទូរស័ព្ទលេខ **០១២ ៧៥ ២៣ ៥៧ ០១២ ៩៨ ៤៤ ៧២** ។

បាត់ដំបង, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦

**អភិបាលខេត្ត**

**ចំរើន សុជល**